សំណើ 50

# ការព្យួរនូវនីតិបុគ្គល។ វិសោធនកម្មរដ្ឋធម្មនុញ្ញអង្គនីតិបញ្ញត្តិ។

## មាត្រា និងសេចក្តីសង្ខេប ជាផ្លូវការ

បានរៀបចំដោយអគ្គមេធាវី

- អនុញ្ញាតឲ្យវិមានអង្គនីតិបញ្ញត្តិនីមួយៗ ព្យួរសមាជិកម្នាក់របស់ខ្លួន ដោយមានសំឡេងឆ្នោត ពីរ-ភាគបី និងតម្រូវឲ្យសមាជិកបោះបង់ប្រាក់ខែ និងអត្ថប្រយោជន៍ ក្នុងខណៈត្រូវបានព្យួរ។
- ហាមឃាត់សមាជិកដែលបានព្យួរ ពីការប្រើសិទ្ធិ ឯកសិទ្ធ ភារៈកិច្ច ឬអំណាចនៃការិយាល័យ ឬការប្រើប្រាស់ធនធានអ្វីមួយរបស់អង្គនីតិបញ្ញត្តិ។
- ផ្តល់ការព្យួរ អាចនឹងចប់នៅកាលបរិច្ឆេទជាក់លាក់ ឬនៅពេលមានសំឡេងឆ្នោតពីរ-ភាគបី នៃវិមានរបស់សមាជិក។

### សេចក្តីសង្ខេបការវិភាគនៃអង្គនីតិបញ្ញត្តិ ស្មានពីឥទ្ធិពលហិរញ្ញវត្ថុ បានមករបស់រដ្ឋាភិបាលរដ្ឋ និងមូលដ្ឋាន:

- គ្មានផលប៉ះពាល់ទៅលើការចំណាយរបស់រដ្ឋ ក្នុងឆ្នាំភាគច្រើន។ នៅឆ្នាំខ្លះ រដ្ឋតូចៗសន្សំ សំចៃប្រាក់បាន។

### បោះឆ្នោតផ្តាច់ព្រ័ត្រដោយអង្គនីតិបញ្ញត្តិ ស្តីពី SCA 17 (សំណើ 50) (ជំពូកដំណោះស្រាយ 127, លក្ខន្តិកៈនៃឆ្នាំ 2014)

| | | |
|---|---|---|
| ព្រឹទ្ធសភាៈ | យល់ព្រម 31 | ជំទាស់ 3 |
| សភាៈ | យល់ព្រម 73 | ជំទាស់ 2 |

50

## ការវិភាគ ដោយអ្នកវិភាគនីតិបញ្ញត្តិ

### សាវតារ

***អង្គនីតិបញ្ញត្តិរដ្ឋកាលីហ្វ័រនីញ៉ា។*** ជារៀងរាល់ឆ្នាំ អង្គនីតិបញ្ញត្តិបោះឆ្នោតដើម្បីយល់ព្រម ឬបដិសេធសំណើច្បាប់ និងអនុម័តគំរោងថវិការដ្ឋ។ អ្នកបោះឆ្នោតជ្រើសរើសសមាជិក 120 នាក់ ទៅវិមានអង្គនីតិបញ្ញត្តិពីរ គឺៈ ព្រឹទ្ធសភា 40 នាក់ និងសមាជិកសភា 80 នាក់។ គណៈកម្មការឯករាជ្យមួយ—មិនមែនជាអង្គនីតិបញ្ញត្តិ—កំណត់ប្រាក់ខែ និងអត្ថប្រយោជន៍សំរាប់នីតិបុគ្គល។ នៅពេលបច្ចុប្បន្ននេះ រដ្ឋបើកប្រាក់ខែឲ្យនីតិបុគ្គលភាគច្រើន ប្រហែល $100,000 ក្នុងមួយឆ្នាំ។ នីតិបុគ្គលក៏ទទួលអត្ថប្រយោជន៍សុខភាព ធ្មេញ និងចក្ខុវិស័យដែរ។ គេមិនទទួលអត្ថប្រយោជន៍ប្រាក់និវត្តន៍រដ្ឋទេ។

***ទណ្ឌកម្មនីតិបុគ្គល។*** នៅពេលនីតិបុគ្គលបានជាប់ចោទនៃការប្រព្រឹត្តខុស មានរបៀបជាច្រើនដែលគេអាចបានទទួលទណ្ឌកម្ម។ ឧទាហរណ៍ គេអាចត្រូវបានយកមកកាត់ទោស និងត្រូវបានវិនិច្ឆ័យទោសដោយតុលាការ បើគេ ប្រព្រឹត្តល្មើសច្បាប់ឧក្រិដ្ឋកម្ម ឬអ្នកបោះឆ្នោតប៉ុនប៉ងដកគេចេញពីតំណែងតាមរយៈវិធីដកហូតតំណែង។ លើសពីនេះទៀត វិមាននិមួយៗនៃអង្គនីតិបញ្ញត្តិ តាមទំលាប់មានសមត្ថភាពដើម្បីដាក់ទណ្ឌកម្មសមាជិករបស់ខ្លួន។ លើកលែងតែសំរាប់ការបណ្តេញចោល (រៀបរាប់ នៅខាងក្រោម) តាមសំឡេងឆ្នោតភាគច្រើននៃវិមានបានតម្រូវដើម្បីដាក់ទណ្ឌកម្ម។ វិធានការទណ្ឌកម្មទាំងនេះរួមមាននៅខាងក្រោមៈ

- ***ការបណ្តេញចោល។*** ការបណ្តេញនីតិបុគ្គលម្នាក់—ការបញ្ចប់អាណត្តិនៃតំណែងរបស់គាត់—គឺជាវិធានការទណ្ឌកម្មធ្ងន់ធ្ងរបំផុត ដែលមានសំរាប់សភា ឬព្រឹទ្ធសភា។ ពេលចុងក្រោយបំផុតដែលការនេះបានកើតឡើង គឺនៅឆ្នាំ 1905 នៅពេលព្រឹទ្ធសភាបួននាក់ ត្រូវបានរកឃើញដោ យព្រឹទ្ធសភា ថាមានការស៊ីសំណូក។ បន្ទាប់ពីនីតិបុគ្គលម្នាក់ត្រូវបានបណ្តេញចេញមក គាត់លែងជាសមាជិកសភា ឬព្រឹទ្ធសភាទៀតហើយ។ ប្រាក់ខែ និងអត្ថប្រយោជន៍របស់គាត់ក៏បញ្ឈប់ ។ នៅក្រោមរដ្ឋធម្មនុញ្ញរដ្ឋ ពីរ-ភាគបី នៃសភា ឬព្រឹទ្ធសភា ត្រូវតែបោះឆ្នោត ដើម្បីបណ្តេញសមាជិកម្នាក់របស់ខ្លួន។ នេះគឺជាវិធានការទណ្ឌកម្មដែលបានថ្លែងជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញរដ្ឋ។

## ការវិភាគ ដោយអ្នកវិភាគនីតិបញ្ញត្តិ

បន្ត

- ***ការព្យួរងារ។*** វិមាននិមួយៗនៃអង្គនីតិបញ្ញត្តិ ក៏អាចព្យួរងារសមាជិកម្នាក់របស់ខ្លួនដែរ។ ឧទាហរណ៍ នៅឆ្នាំ 2014 មានព្រឹទ្ធសភាបីនាក់ ត្រូវបានជាប់ចោទនៃបទឧក្រិដ្ឋ ហើយជាលទ្ធផល ព្រឹទ្ធសភាក៏បានបោះឆ្នោតដើម្បីព្យួរគេ។ នៅក្នុងអំឡុងពេលដែលគេត្រូវបានព្យួរងារ ព្រឹទ្ធសភាទាំងបីនាក់នោះមិនបានបោះឆ្នោតទៅលើគំរោងច្បាប់ ឬចាត់វិធានការចំពោះនីតិបញ្ញត្តិផ្សេងៗទៀតឡើយ។ គេនៅមានមុខតំណែងដដែល តែជាយ៉ាងណាមិញ និងក៏រក្សាការទទួលប្រាក់ខែ និងអត្ថប្រយោជន៍របស់រដ្ឋ រហូតទាល់តែគេចាកចេញពីព្រឹទ្ធសភា។ (នៅពេលក្រោយមកក្នុងឆ្នាំ 2014 ម្នាក់ៗ នៃអ្នកទាំងបីនាក់ បានលាលែងតំណែង ឬចាកចេញពីអង្គនីតិបញ្ញត្តិ នៅចុងកាលវិភាគនៃអាណត្តិព្រឹទ្ធសភារបស់គេ)។ នេះគឺជាលើកដំបូង ហើយនៅក្នុងប្រវត្តិសាស្ត្រ ដែលនីតិបុគ្គលរដ្ឋកាលីហ្វ័រនីញ៉ា ត្រូវបានព្យួរងារ។
- ***វិធានការទណ្ឌកម្មផ្សេងទៀត។*** ជាបន្ថែមទៅលើការបណ្តេញចោល និងការព្យួរងារ វិមាននិមួយៗនៃអង្គនីតិបញ្ញត្តិ អាចចាត់វិធានការទណ្ឌកម្មផ្សេងទៀត ដែលមិនសូវធ្ងន់ធ្ងរ។ ទាំងនេះរួមមាននូវការរិះគន់ខ្លាំង (ការទិតៀននីតិបុគ្គលជាសាធារណៈ)។

## សំណើ

***ប្រការបញ្ញត្តិរដ្ឋធម្មនុញ្ញ អំពីការព្យួរងារ។*** វិធានការនេះកែប្រែរដ្ឋធម្មនុញ្ញរដ្ឋ ដើម្បីបន្ថែមប្រការបញ្ញត្តិថ្មី ស្តីពីការព្យួរងាររបស់នីតិបុគ្គល។ ប្រការបញ្ញត្តិដោះស្រាយរឿងរ៉ាវនៅខាងក្រោមៈ

- ***ការតម្រូវសំឡេងឆ្នោតខ្ពស់ជាង ដើម្បីព្យួរងារនីតិបុគ្គល។*** នៅពេលបច្ចុប្បន្ននេះ សភា ឬព្រឹទ្ធសភា អាចព្យួរងារនៃសមាជិកម្នាក់របស់ខ្លួន ដោយមានសំឡេងឆ្នោតភាគច្រើន។ វិធានការនេះតម្រូវឲ្យមានសំឡេងឆ្នោតពីរ-ភាគបី នៃសភា ឬព្រឹទ្ធសភា ទើបអាចព្យួរងារនៃសមាជិកម្នាក់របស់ខ្លួនបាន។
- ***អនុញ្ញាតការព្យួរងារនីតិបុគ្គល ដោយមិនបើកប្រាក់ខែ និងអត្ថប្រយោជន៍។*** នៅពេលបច្ចុប្បន្ននេះ នីតិបុគ្គលដែលត្រូវបានព្យួរងារ នៅរក្សាការទទួលប្រាក់ខែ និងអត្ថប្រយោជន៍របស់រដ្ឋ។ វិធានការនេះអនុញ្ញាតឲ្យសភា ឬព្រឹទ្ធសភា ដើម្បីបញ្ឈប់ការបើកប្រាក់ខែ និងអត្ថប្រយោជន៍របស់នីតិបុគ្គល ក្នុងអំឡុងពេលទាំងអស់ ឬផ្នែកខ្លះនៃការព្យួរងារ។
- ***ការតម្រូវផ្សេងទៀត សំរាប់ការព្យួរងារនីតិបុគ្គល។*** វិធាននេះក៏ (1) ហាមឃាត់នីតិបុគ្គលដែលត្រូវបានព្យួរងារ ពីការបោះឆ្នោតទៅលើច្បាប់ ឬចាត់វិធានការផ្សេងទៀត ឋានៈជានីតិបុគ្គលម្នាក់ ក្នុងអំឡុងពេលនៃការព្យួរងារ, (2) តម្រូវឲ្យវិមាន រៀបរាប់ពីមូលហេតុសំរាប់ការព្យួរងារ, និង (3) ចែងវិន័យសំរាប់ការព្យួរងារនឹងចប់នៅពេលណា (ទោះបើនៅកាលបរិច្ឆេទជាក់លាក់ ដែលបានចែងដោយសភា ឬព្រឹទ្ធសភា ឬបន្ទាប់ពីមានសំឡេងឆ្នោតពីរ-ភាគបីនៃសភា ឬព្រឹទ្ធសភា ដើម្បីបញ្ចប់ការព្យួរងារ។)

## ឥទ្ធិពលហិរញ្ញវត្ថុ

តែនៅក្នុងករណីដ៏កម្រប៉ុណ្ណោះ ដែលនីតិបុគ្គលរដ្ឋកាលីហ្វ័រនីញ៉ា ត្រូវបានបណ្តេញ ឬបានព្យួរងារ។ បើសិនទោសពិន័យនៃទណ្ឌកម្មបែបនោះ ប្រឆាំងនឹងនីតិបុគ្គលបន្តជាកម្រមាន វិធានការនេះនឹងពុំមានឥទ្ធិពលដល់ហិរញ្ញវត្ថុរបស់រដ្ឋ ឬមូលដ្ឋានភាគច្រើននៃឆ្នាំ។ នៅក្នុងឆ្នាំណាមួយនៅអនាគត នៅពេលព្រឹទ្ធសភា ឬសភា បានព្យួរងារនីតិបញ្ញត្តិម្នាក់ វិធានការនេះអាចនឹងបន្ទាបតម្លៃការចេញសងប្រាក់ឲ្យអង្គនីតិបញ្ញត្តិ បណ្តាលរដ្ឋសន្សំប្រាក់បានបន្តិចបន្តួច។

**មើល *http://www.sos.ca.gov/measure-contributions* សំរាប់បញ្ជីនៃគណៈកម្មាធិការដែលបានបង្កើតឡើងជាបឋម ដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។**

**មើល *http://www.fppc.ca.gov/transparency/top-contributors/june-2016-primary-election.html* ដើម្បីមើលអ្នកបរិច្ចាគកំពូល 10 នាក់ របស់គណៈកម្មាធិការ។**

*សំរាប់អត្ថបទពេញលេញ នៃសំណើ 50 មើលទំព័រ 26។*